# ពួកគ្រូ និងហោរាខុសឆ្គង False Teachers and Prophets

សូមអានអត្ថបទទាំងនេះព្រមទាំងឆ្លើយនិងសំនួរផងៈ

១. ២ពេត្រុស ២:១-២ នៅក្នុងខ១ តើលោកពេត្រុសបានព្រមានដល់ពួកគ្រីស្ទបរិស័ទអំពីរឿងអ្វី?

តើនឹងមានមនុស្សជាច្រើនដើរតាមគ្រូខុសឆ្គងទាំងនេះឬ?

២. ១យ៉ូហាន ៤:១ តើរាស្ត្ររបស់ព្រះទទួលបង្គាប់ឱ្យធ្វើអ្វីខ្លះ?

តើមូលហេតុអ្វីបានជាព្រះអង្គបង្គាប់ឱ្យពួកគេធ្វើដូចនេះ?

៣. វិវរណៈ ២:២ តើពួកជំនុំអេភេសូរបានធ្វើកិច្ចការល្អអ្វីខ្លះ?

៤. ២កូរិនថូស ១១:១៣-១៥ សំបកក្រៅរបស់គ្រូខុសឆ្គងមើលទៅដូចអ្វី?

៥. ចោទិយកថា ១៨:២០ នៅក្នុងខនេះ ព្រះជាម្ចាស់បានហាមរាស្ត្ររបស់ទ្រង់ឱ្យប្រុងប្រយ័ត្នចំពោះមនុស្សម្នាក់។ តើមនុស្សម្នាក់នោះជាអ្នកណា?

៦. ចោទិយកថា ១៣:១-៥ នៅក្នុងអត្ថបទនេះ មានហោរាម្នាក់បានប្រកាសពីការអស្ចារ្យ។

តើការអស្ចារ្យនោះបានកើតឡើងឬទេ?

បើសិនជាការអស្ចារ្យបានកើតឡើងមែន តើនោះមានន័យថា អ្នកនោះជាហោរាពិតមែនឬ?

ហេតុអ្វីបានជារាស្ត្ររបស់ព្រះមិនគួរស្តាប់តាមហោរាប្រភេទនោះ?

ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឱ្យមនុស្សយ៉ាងនោះកើតមកលើផែនដី?

ដូច្នេះ ដូចដែលយើងបានឃើញហើយតាមរយៈចោទិយកថា ១៣:១-៥ ថា ទោះបីជាមានអ្នកណាម្នាក់ ដែលអាចធ្វើការអស្ចារ្យ ឬអាចប្រាប់ពីរឿងនៅថ្ងៃអនាគតបានយ៉ាងត្រឹមត្រូវ នោះមិនមែនមានន័យថា រាស្ត្ររបស់ព្រះអង្គត្រូវតែស្តាប់តាមអ្នកនោះទេ។ ប្រសិនបើអ្នកនោះបង្រៀនគោលលទ្ធិខុសឆ្គង នោះយើងមិនគួរស្តាប់តាមឡើយ។ នៅក្នុងពួកអ៊ីស្រាអែល ព្រះបានបង្គាប់ឱ្យសំឡាប់ហោរាក្លែងក្លាយចោល ដូច្នេះការដែលមិនត្រូវស្តាប់តាមហោរាក្លែងនេះគឺជារឿងដ៏សំខាន់មួយ។

៧. ម៉ាថាយ ១២:៣៨-៣៩, ១៦:១-៤ តើព្រះយេស៊ូវគ្រីស្ទពណ៌នាអំពីពួកអ្នកដែលចង់បានទីសំគាល់ថាជាមនុស្សបែបណា?

៨. ២ថែស្សាឡូនីច ២:៨-១០ នៅក្នុងខទី៩ តើអាទទឹងច្បាប់ (គ.ខ.ប. បកប្រែថា «មេប្រឆាំងសាសនា») នឹងមានអំណាចធ្វើអ្វីខ្លះ?

តើនឹងមានអ្វីកើតឡើង (ខ១០)?

ហេតុអ្វីបានជាពួកបណ្តាជនត្រូវវិនាស (ខ១០)?តាមរយៈអត្ថបទខាងលើយើងឃើញថា វាមានសារៈសំខាន់ណាស់សំរាប់រាស្ត្ររបស់ព្រះអង្គក្នុងការដើរតាមសេចក្តីពិត និងចៀសចេញពីការបង្រៀនខុសឆ្គង។ យើងទទួលអ្នកណាម្នាក់ថាជាគ្រូបង្រៀនត្រឹមត្រូវ ហើយដើរតាមសេចក្តីបង្រៀនរបស់អ្នកនោះ មិនមែនដោយព្រោះតែការអស្ចារ្យឬទីសំគាល់ដែលអ្នកនោះធ្វើ ឬដោយព្រោះតែអ្នកនោះទាយទំនាយបានត្រឹមត្រូវ ឬដោយព្រោះអ្នកនោះប្រកាសខ្លួនថាជាគ្រីស្ទាន ឬដើរតាមព្រះយេស៊ូវគ្រីស្ទនោះទេ ដ្បិតអីសាតាំងឆ្លាតវៃណាស់ក្នុងការនាំមនុស្សឱ្យដើរតាមផ្លូវខុស។ សាតាំងដឹងថា មនុស្សងាយត្រូវបានបោកប្រាសតាមរយៈការអស្ចារ្យផ្សេងៗដូចជា ការទាយឆុត ឬទីសំគាល់ផ្សេងៗទៀត។ ដូច្នេះ វាអាចអូសទាញមនុស្សម្នាក់ឱ្យវង្វេងតាមពួកគ្រូខុសឆ្គងតាមរយៈការ អស្ចារ្យទាំងអស់នេះបាន។

មនុស្សជាច្រើនចូលចិត្តស្វែងរកបទពិសោធន៍អស្ចារ្យ គឺជាបទពិសោធដែលខ្ពស់ជាងបទពិសោធន៍ធម្មតា ដែលមនុស្សធ្លាប់មាននៅក្នុងលោកនេះ។ ពួកគេគិតថានៅពេលដែលពួកគេមានបទពិសោធន៍ដ៏អស្ចារ្យទាំងនេះ នោះពួកគេនឹងបានចូលទៅក្នុងពិភពមួយទៀតដែលមិនមែនជាពិភពរបស់មនុស្ស តែជាពិភពរបស់ "ព្រះ" ឬពិភពរបស់ "វិញ្ញាណ" ឬពិភពរបស់ "ទេវតា" វិញ។ ពួកគេប្រហែលជាស្វែងរកបទពិសោធន៍ទាំងនេះតាមរយៈពិធីកម្មសាសនាដូចជាការតាំងសមាធិ អភូតហេតុ មន្តអាគម ឬតាមពិធីផ្សេងៗជាច្រើនទៀត។ ដូច្នេះហើយបានជាសាសនាខុសឆ្គងនៅជុំវិញពិភពលោកមានពេញទៅដោយមនុស្សដែលស្វែងរកបទពិសោធន៍ និងអំណាចទាំងអស់នេះ។ ចំនែកឯព្រះអម្ចាស់យេស៊ូវគ្រីស្ទវិញ ទ្រង់បានមានបន្ទូលយ៉ាងច្បាស់ថា ការដែលខិតខំស្វែងរកទីសំគាល់ ឬការអស្ចារ្យនោះគឺជារឿងដ៏អាក្រក់មួយ។ ប៉ុន្តែ ចំពោះរឿងនេះ ជួនកាលគ្រីស្ទបរិស័ទក៏ធ្លាប់ធ្វើខុសដូចនេះផងដែរ។ នៅពេលដែលមានអ្នកណាម្នាក់បានមក ហើយបានធ្វើការអស្ចារ្យ ឬធ្វើកិច្ចការអ្វីមួយដែលមានលក្ខណៈអស្ចារ្យ ឬក៏ប្រកាសថានឹងធ្វើការអស្ចារ្យ ឬ ធ្លាប់មានបទពិសោធន៍ទទួលការអស្ចារ្យដែលគ្រីស្ទបរិស័ទដ៏ទៃទៀតមិនធ្លាប់មាន ហើយពួកគេបានប្រកាសថា ពួកគេមកក្នុងនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ នោះមនុស្សម្នាជាច្រើនបានដើរតាមអ្នកនោះភ្លាម ដោយគ្មានការគិតពិចារណាអ្វីទាំងអស់។ ប៉ុន្តែយើងឃើញថា នៅពេលដែលពួកមនុស្សដើរតាមលំអាននេះដោយមានមូលដ្ឋានលើការអស្ចារ្យ នោះពួកគេក៏ធ្លាក់ទៅក្នុងការបោកបញ្ឆោតយ៉ាងងាយបំផុត។ ពួកគេគិតថា បទពិសោធន៍អស្ចារ្យទាំងនេះគឺជា "ការបើកសំដែង" ប៉ុន្តែតាមពិតទៅនោះអាចជាការបោកបញ្ឆោត។

ដូច្នេះ វាស្រ្តរបស់ព្រះអង្គត្រូវល្បងលដល់ពួកគ្រូៗ ដើម្បីឱ្យដឹងច្បាស់ថាសេចក្តីបង្រៀនរបស់ពួកគេត្រឹមត្រូវឬអត់។ ម្យ៉ាងទៀត យើងស្គាល់សេចក្តីពិតតាមរយៈព្រះគម្ពីរ ដែលជាការបើកសំដែងប្រកបដោយអំណាចរបស់ព្រះអង្គ។ នោះមានន័យថា យើងអាចស្គាល់ពីការបើកសំដែងរបស់ព្រះជាម្ចាស់តាមរយៈការស្វែងយល់ព្រះបន្ទូលរបស់ទ្រង់គឺជាព្រះគម្ពីរនេះឯង។ ដូច្នេះ យើងត្រូវប្រើគំនិតប្រាជ្ញារបស់យើងដើម្បីសិក្សាព្រះបន្ទូលរបស់ទ្រង់ទាំងនេះ។ នេះគឺជាហេតុផលមួយផ្សេងទៀតដែលមនុស្សម្នាងាយស្រួលធ្លាក់ទៅក្នុងការបោកបញ្ឆោត នៅពេលដែលគ្រូប្រកាសពីបទពិសោធន៍អស្ចារ្យ។ មនុស្សខ្ជិលហើយមិនសូវសិក្សានិងគិតថា វាជាការងាយស្រួលជាងក្នុងការអនុវត្តតាមបទពិសោធន៍ដ៏អស្ចារ្យ។ មនុស្សភាគច្រើនចូលចិត្តអ្វីៗដែលទាក់ទងនិងអារម្មណ៍ ការអស្ចារ្យ ការរំភើបឬរំជួលចិត្ត ភាពងាយ និងភ្លាមៗជាជាងការប្រើគំនិត ប្រាជ្ញាក្នុងការសិក្សាស្រាវជ្រាវលើអត្ថបទព្រះគម្ពីរ។ តាមរយៈវិធីសាស្រ្តទាំងនេះឯងដែលសាតាំងមានភាពងាយស្រួលក្នុងការបោកប្រាសដល់មនុស្ស។ នៅក្នុងពួកជំនុំសព្វថ្ងៃ នេះមានពួកគ្រូខុសឆ្គងជាច្រើនបានលេចឡើង។ គេបង្រៀនអំពីព្រះគ្រីស្ទ តែបានបង្រៀនគោលលទ្ធិខុសឆ្គងយ៉ាងច្រើន ដូចដែលព្រះគម្ពីរបានបង្រៀនយើងឱ្យដឹងរួចហើយថា នឹងមានមនុស្សជាច្រើនដើរតាមសេចក្តីបង្រៀនខុសឆ្គងនេះ។

ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏លោកប៉ុលបានលើកយកគំរូពីអ្នកដឹកនាំគ្រីស្ទានដែលមាន លក្ខណៈផ្ទុយពីគ្រូខុសឆ្គងទាំងអស់នេះមកបង្ហាញយើងឱ្យដឹងផងដែរ។ ដូចជានៅក្នុង ២កូរិនថូស ១២:១-៦ យើងឃើញថា លោកប៉ុលបានមានបទពិសោធន៍ដ៏អស្ចារ្យច្រើនលើកច្រើនសារ ហើយលោកក៏ធ្លាប់មានបទពិសោធន៍ទទួលនូវការបើកសំដែងមកពីព្រះជាម្ចាស់ផងដែរ។ ប៉ុន្តែយើងឃើញថា លោកប៉ុលមិនបានអួត ឬប្រកាសពីបទពិសោធន៍ដែលគាត់ធ្លាប់មាននោះទេ។ គាត់ មិនចង់ឱ្យអ្នកណាម្នាក់ដឹងអំពីការបើកសំដែងទាំងនេះទេ ហេតុនេះហើយបានជាលោកមិនដែលប្រាប់អ្នកណាឱ្យដឹង។ មូលហេតុដែលគាត់មិនព្រមនិយាយឱ្យអ្នកណាដឹង ពីព្រោះគាត់ព្រួយបារម្ភខ្លាចក្រែងថា នៅពេលដែលលោកនិយាយប្រាប់ហើយ នោះពួកមនុស្សនឹងគិតខ្ពស់ពីលោក ឱ្យតំលៃខ្ពស់ដល់រូបលោក។ មានមនុស្សជាច្រើនដែលចំណាយពេលយ៉ាងច្រើនរបស់ខ្លួនដើម្បីស្វែងរកមុខមាត់ក្នុងសង្គមព្រោះភ័យខ្លាចក្រែងមនុស្សដ៏ទៃគិតទាបអំពីខ្លួន ឱ្យតំលៃដល់ខ្លួនទាប ដែលទង្វើបែបនេះផ្ទុយពីគំនិតរបស់ប៉ុលទាំងស្រុង។ គាត់ដឹងថា ប្រសិនបើគាត់និយាយប្រាប់ពួកបណ្តាជនថា គាត់បានទទួលការបើកសំដែងដ៏អស្ចារ្យមកពីព្រះជាម្ចាស់ នោះពួកបណ្តាជននឹងគិតខ្ពស់ ឬឱ្យតំលៃខ្ពស់ដល់រូបលោក ដូច្នេះហើយបានជាលោកសំរេចក្នុងចិត្តថា នឹងមិននិយាយប្រាប់ពីការនេះដល់អ្នកណាឡើយ។ នៅក្នុងគំនិតរបស់គាត់ គឺគាត់ចង់ឱ្យពួកបណ្តាជនទទួលស្គាល់គាត់ជាអ្នកដឹកនាំម្នាក់តាមរយៈអ្វីដែលគាត់បាននិយាយ និងធ្វើ មិនមែនតាមរយៈបទពិសោធន៍អស្ចារ្យនោះទេ ដែលនេះគឺជាគំនិត ហើយក៏ជាទង្វើដ៏ត្រឹមត្រូវដែរ។ នោះមានន័យថា ពួកបណ្តាជនគួរតែទទួលស្គាល់អ្នកដឹកនាំ តាមរយៈគំរូក្នុងជីវិត និងតាមរយៈ ការសាកល្បងឬល្បងលសេចក្តីបង្រៀនរបស់គ្រូបង្រៀន។ តើគ្រូនោះបង្រៀនពីសេចក្តីពិតនៅក្នុងព្រះគម្ពីរ ឬទេ។ នេះហើយជាការទទួលស្គាល់ ឬវាយតំលៃដែលប្រកបដោយភាពចាស់ទុំ និងពេញវ័យខាងសេចក្តី ជំនឿ។

សំនួរ

១. តើសាតាំងអាចបំភាន់មនុស្សបានយ៉ាងងាយដោយរបៀបណា?

២. ហេតុអ្វីបានជាបទពិសោធន៍អធិធម្មជាតិងាយស្រួលក្នុងនាំមនុស្សឱ្យវង្វេង?

៣. តើប៉ុលគឺជាគំរូម្នាក់ដ៏ល្អដោយរបៀបណា?

៤. តើគ្រូបង្រៀនបែបណាដែលយើងគួរស្តាប់ ឬដើរតាម?